សម្លេងខ្មែរនៅបរទេស

# ឯកសារប្រវត្តិសាស្ត្រ

ដកស្រង់ចេញពីសៀវភៅនៃក្រសួងឃោសនាការជាតិ

**DOCUMENTS SUR L'AGRESSION VIETCONG ET NORD-VIETNAMIENNE CONTRE LE CAMBODGE (1970)**

# អំពើឈ្លានពានដ៏ស្ងាត់ស្ងៀម ឆ្នាំ១៩៦៩

## L'invasion silencieuse (1969)

(បកប្រែក្រៅផ្លូវការ)

នៅខែឧសភានិងមិថុនាឆ្នាំ១៩៦៧, គឺ៣ឆ្នាំមុនពេលបើកការវាយប្រហារយ៉ាងចំហមកលើប្រទេសកម្ពុជាអព្យាក្រឹត្យនិងសន្តិភាព ពួកយួនកុម្មុយនិស្ត (យៀកណាមខាងជើងនិងរណសិរ្សរំដោះជាតិ) បានទទួលស្គាល់ព្រំដែនបច្ចុប្បន្នរបស់យើង ហើយបានសន្យាគោរពជាឧឡារិកក៏ដូចគ្នានឹងឯករាជភាព, អធិបតេយ្យភាព ព្រមទាំងអព្យាក្រឹត្យភាពនៃប្រទេសរបស់យើងផងដែរ ។

មកដល់ពេលឥឡូវនេះ, ទោះបីមានកិច្ចសន្យាជាលាយល័ក្ខអក្សរយ៉ាងណាក៏ដោយ, កងកម្លាំងយៀកកុង-យៀកណាមខាងជើង បានបន្តនូវការជ្រៀតចូលមកលើទឹកដីខ្មែរ ជាទីកន្លែងដែលពួកគេបានចាប់ផ្តើមតាំងទីជំរកជាច្រើនឆ្នាំកន្លងមកហើយ ក្រោមការឃុបឃិតរបស់ស្តេចសីហនុ ។

ឆ្នាំ១៩៦៨ (ឆ្នាំបើកការវាយប្រហារនារដូវបុណ្យចូលឆ្នាំយួន) និងឆ្នាំ១៩៦៩, ការជ្រៀតចូលទាំងនេះកាន់តែមានទំហំរីកធំឡើងៗជាលំដាប់ដែលអតីតប្រមុខរដ្ឋខ្មែរពុំអាចបដិសេធតទៅទៀតបាន ។ «ជំរក»យៀកកុងនៅក្នុងពេលជាមួយគ្នាបានរាលដាលដ៏សំបើមអស្ចារ្យ គឺក្លាយជាមូលដ្ឋានយោធាបរទេសយ៉ាងពិតប្រាកដ តាំងទីនៅលើទឹកដីរបស់យើងដោយប្រមាថមើលងាយចំពោះអព្យាក្រឹត្យភាព និងក្រោយពីមានអំពើរំលោភរាប់មិនអស់លើព្រំដែនមក ។

សូមបញ្ជាក់ថា ការប្រើប្រាស់កាន់តែខ្លាំងឡើងៗនៃទឹកដីខ្មែរដោយកងកម្លាំងយៀកកុង-យៀកណាមខាងជើងនេះ, ស្តេចសីហនុខ្លួនឯងក៏បានប្តឹងជំទាស់ជាញឹកញាប់ចំពោះអំពើជ្រៀតចូលនិងការតាំងទីរបស់ពួកកុម្មុយនិស្ត ពេញមួយរយៈពេលឆ្នាំ១៩៦៩ ។ ក្នុងឆ្នាំដដែលផងដែរ ក៏មានការប៉ះទង្គិចគ្នាយ៉ាងច្រើនរវាងកម្លាំងការពារយើង ជាមួយពួកយៀកកុង-យៀកណាមខាងជើង នៅលើទឹកដីយើង ។ ដំណើរឧប្បត្តិហេតុនេះ (បណ្តាលឲ្យមានការស្លាប់និងរបួសទាំងសង្ខាង) ទាហានយៀកកុង-យៀកណាមខាងជើងមួយចំនួន បានត្រូវកម្លាំងការពាររបស់យើងចាប់បានខ្លួនមួយចំនួន ដែលនៅពេលក្រោយមកបានត្រូវដោះលែងឲ្យរួចខ្លួនទៅវិញក្រោមបញ្ជានៃស្តេចសីហនុ ។

មួយវិញទៀតគួរកត់សំគាល់ថា ចាប់តាំងពីឆ្នាំ១៩៦៩មក ពួកកុម្មុយនិស្តយួនបានបង្កឲ្យមានការងើបបះបោរនៃពួកកុលសម្ព័ន្ធភ្នំ (ខ្មែរលើ) នៅក្នុងខេត្តរតនគីរីរបស់យើង ដែលជាកន្លែងប្រតិបត្តិការយោធាកើតឡើងនៅក្នុងឆ្នាំ១៩៦៩ ប្រឆាំងឯកភាពយៀកកុង-យៀកណាមខាងជើង ដែលបានចូលមកតាំងទីនៅក្នុងខេត្តនេះ (ទិសខាងជើងនៃទន្លេសេសាន) ។ គួរកត់សំគាល់ផងដែរថា ពួកយៀកកុង-យៀកណាមខាងជើង បានគាំទ្រយ៉ាងសកម្មដល់ក្រុមបះបោរខ្មែរក្រហមកុម្មុយនិស្ត ដែលមានកងទ័ពស្ថិតនៅក្រោមបញ្ជាការរបស់ខ្លួន ។

ឯកសារតទៅនេះ គឺទាក់ទងនឹងអំពើឈ្លានពានយ៉ាងស្ងាត់ស្ងៀមមកលើទឹកដីខ្មែរ នៃកងកម្លាំងយៀកកុង-យៀកណាមខាងជើង ដែលជាការចាប់ផ្តើមឡើងនៃអំពើឈ្លានពានយ៉ាងចំហប្រឆាំងកម្ពុជាក្នុងឆ្នាំ១៩៧០ ។

សំបុត្ររបស់នាយករដ្ឋមន្ត្រីយៀកណាមខាងជើង ផាំម-យ៉ាងដុង ផ្ញើថ្វាយស្តេចនរោត្តម-សីហនុ (ថ្ងៃទី៨-៦-៦៧) ដើម្បីប្រកាសឲ្យទ្រង់បានដឹងអំពីការទទួលស្គាល់នៃយៀកណាមខាងជើង ចំពោះព្រំដែនបច្ចុប្បន្នកម្ពុជា ហើយបានសន្យាគោរពថែមទៀតផង ៖


PHỦ THỦ TƯỚNG
NƯỚC VIỆT-NAM DÂN-CHỦ CỘNG-HÒA

Số 30 VP/NG

Hà-nội, ngày 8 tháng 6 năm 1967

Thưa Ngài,

Tôi hân hạnh chuyển đến Ngài bản Tuyên bố ngày 8 tháng 6 năm 1967 của Chính phủ nước Việt-nam dân chủ cộng hoà công nhận biên giới hiện tại của Cam-pu-chia.

Nhân dịp này, thay mặt Chính phủ và nhân dân nước Việt-nam dân chủ cộng hoà, tôi xin nói lên lòng biết ơn chân thành của chúng tôi về sự ủng hộ tích cực và kiên quyết mà Ngài và nhân dân Khơ-me không ngừng dành cho sự nghiệp đấu tranh chính nghĩa và tất thắng của nhân dân Việt-nam chống bọn xâm lược Mỹ, kẻ thù của nhân dân hai nước chúng ta và của nhân dân toàn thế giới.

Kính gửi
SAMDECH NORODOM SIHANOUK
Quốc trưởng
kiêm Chủ tịch Hội đồng Bộ trưởng
Vương quốc Cam-pu-chia
PHNOM-PENH

Tôi tin tưởng vững chắc rằng tình hữu nghị thân thiết và đoàn kết chiến đấu giữa nhân dân hai nước láng giềng anh em chúng ta ngày càng phát triển vì lợi ích của hai nước và vì lợi ích của hoà bình ở Đông-dương và Đông Nam Á.

Xin gửi Ngài lời chào rất kính trọng./.

PHẠM VĂN ĐỒNG
Thủ tướng Chính phủ
nước Việt-nam dân chủ cộng hoà

លិខិតលោកង្វៀង-ហ៊ុយថូ, ប្រធានរណសិរ្សរំដោះជាតិ (FNL) ផ្ញើថ្វាយចំពោះស្ដេចនរោត្ដម-សីហនុ (ថ្ងៃទី៦-៦-៦៧) ប្រកាសឲ្យដឹងអំពីការសំរេចចិត្តនៃគណៈកម្មាធិការកណ្ដាលរណសិរ្សរំដោះជាតិ ទទួលស្គាល់និងគោរពព្រំដែនបច្ចុប្បន្នកម្ពុជា (តាមសេចក្ដីសំរេចចិត្តចុះថ្ងៃទី៣១ ឧសភា ឆ្នាំ១៩៦៧) ៖

(បកប្រែក្រៅផ្លូវការ)

រណសិរ្សរំដោះជាតិ
នៃវៀតណាមខាងត្បូង
លោកង្វៀង-ហ៊ុយថូ
ប្រធានប្រេស៊ីដីយ៉ូម
នៃគណៈម្មាធិការកណ្ដាល
លេខ ៖ ២៥០/CT-1

វៀតណាមខាងត្បូង, ថ្ងៃទី៦ មិថុនា ១៩៦៧

ថ្វាយចំពោះសម្ដេចនរោត្ដម-សីហនុ
ប្រមុខរដ្ឋនៃកម្ពុជា

សម្ដេច,

តាមសេចក្ដីប្រកាសចុះថ្ងៃទី៣១ ឧសភា ឆ្នាំ១៩៦៧, គណៈកម្មាធិការរណសិរ្សជាតិរំដោះនៃវៀតណាមខាងត្បូង បានធ្វើការសំរេចចិត្តឆ្លើយតបជាវិជ្ជមាន ចំពោះការរំពាវនាវនៃរាជរដ្ឋាភិបាលចុះថ្ងៃទី៩ ឧសភា ឆ្នាំ ១៩៦៧ លើការទទួលស្គាល់បូរណភាពទឹកដីនៃកម្ពុជានៅក្នុងព្រំដែនបច្ចុប្បន្ន ។

យើងមាន, តាមរយៈសម្លេងយ៉ាងឆាប់រហ័ស និងមានទំនុកចិត្តចំ-ពោះលោកង្វៀង-យាំងហ៊ីវ, សមាជិកប្រេស៊ីឌីយ៉ូម, បំពេញបេសកកម្មនាំថ្វាយចំពោះសម្ដេចនិងរាជរដ្ឋាភិបាល នូវអត្ថបទនៃការសំរេចចិត្តពីគណៈកម្មាធិការកណ្ដាលរបស់យើង ។

ដើម្បីជាកិច្ចប្រកាសជាឧឡារិកនេះ, ទូលបង្គំសូមបញ្ជាក់យ៉ាងរឹងមាំដោយចំពោះឲ្យមុខរណសិរ្សរំដោះជាតិនិងប្រជាជនវៀតណាមខាងត្បូងធ្វើជាសាក្សីមិត្តភាពពុំអាចបំបែកបានចំពោះបងប្អូនខ្មែរ ។ យើងសូមបន់ស្រន់ឲ្យសេចក្ដីស្រឡាញ់ដ៏រឹងមាំតទៅមុខ ដល់ការចងមិត្តប្រយុទ្ធតស៊ូរវាងប្រជាជននៃប្រទេសទាំងពីរដើម្បីប្រឈមមុខតទល់នឹងសត្រូវឈ្លានពានរួម គឺពួកចក្រពត្តិនិយមអាមេរិកាំងនិងបាវបំរើរបស់វា ។

ខ្ញុំសូមអនុញ្ញាតនៅក្នុងឱកាសនេះ, ប្រសិទ្ធិពរដ៏ឧត្តុងឧត្ដមបំផុតចំ-ពោះប្រជាជនជាមិត្ត, ចំពោះសម្ដេច និងរដ្ឋាភិបាល, សូមឲ្យបានប្រកបដោយជោគជ័យយ៉ាងធំ នៅក្នុងការថែរក្សាអធិបតេយ្យភាព, ឯករាជភាព, អព្យាក្រឹត្យភាព និងបូរណភាពទឹកដីនៃកម្ពុជា ប្រឆាំងចំពោះលកឧបាយនិងអំពើឈ្លានពាននៃពួកចក្រពត្តិនិយមអាមេរិកាំងនិងពួកភ្នាក់ងាររបស់វា ។

ខ្ញុំសូមសម្ដេច ទទួលនូវការស្រឡាញ់និងរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

(ហត្ថលេខា ៖ ង្វៀង-ហ៊ុយថូ)



FRONT NATIONAL DE LIBÉRATION
DU SUD VIETNAM

Me NGUYEN-HUU-THO
PRÉSIDENT DU PRESIDIUM
DU COMITÉ CENTRAL

No: 250/CT-1

Sud Vietnam, le 6 Juin 1967

à Samdech [illegible]
Chef de l'Etat
du
CAMBODGE

Samdech ,

Par Déclaration du 31 Mai 1967, le Comité Central du Front National de Libération du Sud Vietnam a pris la décision de répondre positivement à l'appel du Gouvernement Royal en date du 9 Mai 1967 sur la reconnaissance de l'intégrité territoriale du Cambodge dans ses frontières actuelles .

Nous avons, par les voies les plus rapides, confié à M. Nguyen-van-Hieu, membre du Presidium, la mission de porter à la connaissance de Samdech et du Gouvernement Royal le texte de la décision de notre Comité Central .

En faisant cette solennelle Déclaration, dont je tiens à confirmer les termes par la présente, le Front National et le peuple du Sud Vietnam voudraient témoigner leur amitié indéfectible à l'égard du peuple khmer frère. Nous avons pris en effet à coeur la consolidation continuelle de cette amitié combattante entre nos deux peuples face à l'agression de nos ennemis communs, les impérialistes américains et leurs valets .

T.S.V.P.

Qu'il me soit permis, à cette occasion, de former des souhaits les plus chaleureux au peuple ami, à Samdech et au Gouvernement qu'Il préside pour de grands succès dans la préservation de la souveraineté, de l'indépendance, de la neutralité et de l'intégrité territoriale du Cambodge contre les menées et actes d'agression des impérialistes américains et de leurs agents .

Je Vous prie d'agréer, Samdech, l'assurance de ma haute considération et de mes sentiments affectueux .

CHỦ TỊCH ĐOÀN
UỶ BAN
TRUNG ƯƠNG
CHỦ TỊCH

NGUYEN-HUU-THO

សម្លេងខ្មែរនៅបរទេស

# ឯកសារប្រវត្តិសាស្ត្រ

**DOCUMENTS SUR L'AGRESSION VIETCONG ET NORD-VIETNAMIENNE CONTRE LE CAMBODGE (1970)**

EDITE PAR LE MINISTRE DE L'INFORMATION
PHNOM PENH

ឯកសារសម្ងាត់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី<ឡឺសង្គម>
លេខខែតុលា ឆ្នាំ១៩៦៩

## ទីតាំងយៀកកុងនិងយៀកណាមខាងជើងនៅតាមបណ្ដោយព្រំដែនរបស់យើង

(រយៈពេលចាប់ពីថ្ងៃទី១៦ ដល់ ៣០ ខែកញ្ញា ១៩៦៩)

រាយការណ៍ដោយលោកឧត្ដមសេនីយ៍ទោ លន់-នល់
ប្រធានក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ
(បកប្រែក្រៅផ្លូវការ)



ឧត្ដមសេនីយ៍លន់-នល់

ទូលព្រះបង្គំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ទូលថ្វាយពត៌មានសម្ដេចព្រះប្រមុខរដ្ឋ អំពីទីតាំងសរុបនៃកម្លាំងកងទ័ពយៀកកុងនិងយៀកណាមខាងជើង នៅតាមបណ្ដោយព្រំដែនខ្មែរ-យួនខាងត្បូង សំរាប់ពាក់កណ្ដាល១៥ថ្ងៃចុងក្រោយនៃខែកញ្ញាឆ្នាំ១៩៦៩ ៖

**១- ភិនភាគជាទូទៅ**

ចំនួនសរុបនៃកម្លាំងកងទ័ពបរទេសតាំងនៅលើទឹកដីរបស់យើងនេះ បានកើនចំនួនឡើងចន្លោះពី៣៥,០០០ទៅ៤០,០០០នាក់ គឺកើនឡើងខុសពីចំនួននៅក្នុងសេចក្ដីរាយការណ៍សំរាប់១៥ថ្ងៃដំបូង (ដែលមានចំនួនចន្លោះពី៣២,០០០ទៅ៣៥,០០០នាក់) ។

- ការកើនឡើងគួរឲ្យចាប់អារម្មណ៍ គឺស្ថិតនៅត្រង់ព្រំដែនទិសខាងត្បូងខេត្តមណ្ឌលគិរីនិងខេត្តក្រចេះ ។
- ការកើនឡើងស្រាល គឺនៅក្នុងយោធភូមិភាគទី១ (ខេត្តស្វាយរៀង, ព្រៃវែង និងកណ្ដាល) និងនៅក្នុងយោធភូមិភាគទី២ (ខេត្តតាកែវ) ។

មូលហេតុដែលបណ្ដាលឲ្យមានការផ្លាស់ប្ដូរប្រែប្រួលនេះ គឺការដកថយនៃកងឯកភាពនានារបស់យៀកកុង បន្ទាប់ពីមានទឹកជំនន់ និងគំនាបសង្កត់ប្រតិបត្តិការធ្វើឡើងដោយសត្រូវ ។

**២- ការចែកចាយនៃកម្លាំងទ័ព**

★ **យោធភូមិភាគទី៥** ៖ គេរក្សាចំនួនទាហាននៅក្នុងផ្នែកនេះឲ្យស្ថិតនៅដដែល គឺមាន៥កងវរៈសេនាធំ (ពី៦,០០០ទៅ៧,០០០នាក់) ។

★ **យោធភូមិភាគទី៦** ៖ មានការកើនឡើងគួរឲ្យចាប់អារម្មណ៍ពីចំនួនលេខមុនគឺ១០,០០០នាក់ (កងពលទី៥និងទី៧) ។

★ **យោធភូមិភាគទី១** ៖ មានការកើនឡើងស្រាលនៅក្នុងភូមិភាគទាំងមូល គឺខេត្តស្វាយរៀង, ព្រៃវែង និងកណ្ដាល ។ ចំនួនទាហានបានឡើងពី១២,០០០នាក់ទៅ១៥,០០០នាក់ ។

★ **យោធភូមិភាគទី២** ៖ មានការកើនឡើងបន្តិចបន្តួចប៉ុណ្ណោះ បន្ទាប់ពីមានការដកទ័ពខ្លះចេញពីកងឯកភាពទី៩ និងពីកងពលលេខ១ពី «ភ្នំទាំង៧» នៅខេត្តចូវដុក (គឺពីចំនួន១,៨០០នាក់ទៅ២,០០០នាក់) ។

**៣- សេចក្ដីបញ្ចប់**

ការកើនចំនួនឡើងនៃកម្លាំងកងទ័ពបរទេសនៅលើទឹកដីរបស់យើង គឺបណ្ដាលមកពីប្រតិបត្តិការបោសសំអាត ធ្វើឡើងនៅក្នុងតំបន់យុទ្ធសាស្ត្រទី៤១ ដោយកងកម្លាំងទ័ពអាមេរិកាំង-យៀកណាមខាងត្បូង និងដោយសារទឹកជំនន់ ។ នៅក្នុងរយៈពេលនេះ គ្មានសញ្ញាអ្វីបញ្ជាក់ឲ្យដឹងទាល់តែសោះថា កងឯកភាពបរទេសទាំងអស់នេះ នឹងចាកចេញពីទឹកដីយើងនាអនាគតឆាប់ៗឡើយ ។

ចំនួនការរងគ្រោះប្រថុយប្រថាននៅតែខ្ពស់ដដែល ហើយមានការកើនចំនួនកាន់តែច្រើនឡើងៗនៅតាមបណ្ដោយព្រំដែនក្នុងយោធភូមិភាគទី១ (កងផ្នែកសឹករងខេត្តព្រៃវែង) និងយោធភូមិភាគទី២ ។៚

---

### ខាងក្រោមនេះគឺកំណត់ហេតុដោះលែងទាហានយៀកកុង-យៀកណាមខាងជើង ដែលកងទ័ពយើងបានចាប់ខ្លួនបាន ធ្វើឡើងកាលពីថ្ងៃទី៤ កក្កដា ១៩៦៩ នៅក្រោមព្រះរាជបញ្ជារបស់ស្ដេចសីហនុ

ថ្ងៃសុក្រទី៤ ខែកក្កដា ឆ្នាំ១៩៦៩ វេលាម៉ោង១២ថ្ងៃត្រង់ នៅក្រសួងការបរទេស ធ្វើឡើងរវាងឯ.ឧ.អ៊ុង-ឈុំដេត, អគ្គលេខាធិការក្រសួងការបរទេសនៃរាជរដ្ឋាភិបាលកម្ពុជា និងលោកង្វៀង-បាយ៉ុង, តំណាងស្ថានទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង ក្នុងការដោះលែងសមាជិកចំនួនម្ភៃនាក់នៃរណសិរ្សរំដោះជាតិដែលមានឈ្មោះរាយនៅក្នុងបញ្ជីភ្ជាប់ជាមួយស្រាប់ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៩ មិថុនា ឆ្នាំ១៩៦៩ នៅកំពង់ជ្រៃ ខេត្តព្រៃវែង ដោយកងទ័ពជាតិខ្មែរប្រចាំការនៅត្រង់ទីកន្លែងនោះ ។

លោកង្វៀង-បាយ៉ុង, តំណាងស្ថានទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង បានប្រកាសឲ្យដឹងនៅចំពោះមុខថា សមាជិករណសិរ្សរំដោះជាតិដែលបានចាប់ខ្លួនទាំងម្ភៃរូបនោះ មានសុខភាពល្អ និងបានដោះលែងចេញពីការទទួលខុសត្រូវនៃរាជរដ្ឋាភិបាលកម្ពុជា ចាប់ពីពេលនេះតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី៤ កក្កដា ១៩៦៩

| | |
|---|---|
| ហត្ថលេខា | ហត្ថលេខា |
| ង្វៀង-បាយ៉ុង | អ៊ុង-ឈុំដេត |



# ឯកសារប្រវត្តិសាស្រ្ត

## LIVRE BLANC SUR L'AGRESSION VIETCONG ET NORD-VIETNAMIENNE CONTRE LE CAMBODGE (1970-71)

EDITE PAR LE MINISTRE DE L'INFORMATION
PHNOM PENH

ជាដំបូងយើងសូមដកស្រង់នូវវគ្គមួយក្រោមចំណងជើងថា «នយោបាយស្តេចសីហនុឆ្ពោះទៅរកវៀតណាម» នៅក្នុងសៀវភៅ «តើហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា» (Why Vietnam Invaded Cambodia) សរសេរដោយលោក Stephen J. Morris <p-40 & 41> ដូចតទៅ ៖

«...ចាប់ពីពេលមានកិច្ចក្រុងហ្សឺណែវខែមិថុនាឆ្នាំ១៩៦២, ដែលនៅក្នុងនោះពួកប្រទេសមហាអំណាចប្រកាសឲ្យដឹងថា ស្រុកលាវត្រូវស្ថិតនៅជាស្រុកអព្យាក្រឹត្យ, ស្តេចសីហនុជឿថា ស្រុកលាវមុខជាក្លាយទៅស្រុកកុម្មុយនិស្តចៀសពុំរួច ។ ទ្រង់ក៏មានការបារម្ភភ័យខ្លាចដែរ ចំពោះវាសនាកើតមានឡើងដល់ស្រុករបស់ទ្រង់ ជាពិសេសបើវិបត្តិស្រុកលាវត្រូវផ្លាយហូរចូលមកក្នុងស្រុកខ្មែរ ។ ដោយការមិនពេញចិត្តចំពោះការស្ទាក់ស្ទើរមិនដាច់ស្រេចរបស់សហរដ្ឋអាមេរិក ទៅលើវាសនានៃស្រុកលាវ, ទ្រង់ក៏សំរេចចិត្តថា សន្តិសុខស្រុករបស់ទ្រង់ យកល្អត្រូវផ្អៀងទៅរកពួកប្លុកកុម្មុយនិស្ត និងជាពិសេសឆ្ពោះទៅរកចិន ។ ស្តេចសីហនុសង្ឃឹមថា ការចងមិត្តជាមួយចិន ប្រហែលអាចផ្តល់នូវការធានាខ្លះដល់ស្រុករបស់ទ្រង់ ដើម្បីប្រឆាំងទប់ទល់មហិច្ឆិតារបស់យួនខាងជើង ។ ទ្រង់បានដឹងរួចហើយថា យួនខាងជើងបានប្រើប្រាស់ទឹកដីប្រទេសរបស់ទ្រង់ធ្វើជាផ្លូវលំហូ-ជីមិញ សំរាប់ដឹកជញ្ជូនស្បៀងទៅធ្វើចំបាំងនៅក្នុងស្រុកយួនខាងត្បូង ។

នៅអំឡុងដើមឆ្នាំ១៩៦០, នយោបាយការបរទេសរបស់ស្តេចសីហនុ ក៏ត្រូវបានបង្កើនឥទ្ធិពលផងដែរ ដោយការចោលកំហឹងរបស់ទ្រង់ធ្វើនយោបាយជាខ្មាំងរបស់សហរដ្ឋអាមេរិក និងខ្មាំងរបស់រដ្ឋាភិបាលប្រជុំអាមេរិកាំងនៅថៃនិងយួនខាងត្បូង ។ ក្រុមទ័ពព្រៃ<ខ្មែរសេរី> ដែលគេជឿយ៉ាងពិតប្រាកដថា ជាក្រុមគាំទ្រដោយសេអ៊ីអា (ហើយនិងស្ថិតនៅក្រោមការដឹកនាំរបស់សឺង-ង៉ុកថាន់ សត្រូវប្រឆាំងនយោបាយសីហនុជាយូរឆ្នាំ), បានផ្សាយវិទ្យុឃោសនាប្រឆាំងសីហនុ ចេញពីស្រុកថៃនិងពីស្រុកយួនខាងត្បូង ។ ក្នុងខែសីហាឆ្នាំ១៩៦៣ ស្តេចសីហនុបានកាត់ផ្តាច់ចំណងទូតជាមួយយួនខាងត្បូង ។ ដល់ខែវិច្ឆិកាឆ្នាំដដែល ទ្រង់បញ្ឈប់កម្មវិធីជំនួយយោធាអាមេរិកាំងទាំងអស់នៅក្នុងស្រុកខ្មែរ ។ ក្នុងខែធ្នូឆ្នាំ១៩៦៣, ស្តេចសីហនុបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយយោធាជាលើកទី១ជាមួយប្រទេសចិន ។ ដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៦៥ ស្តេចសីហនុកាត់ផ្តាច់ចំណងទូតជាមួយសហរដ្ឋអាមេរិក ។

ចាប់ពីឆ្នាំ១៩៦៥រហូតមក, ចិន, រុស្ស៊ី និង ឆេកូ បានត្រូវទទួលនូវការអនុញ្ញាតឲ្យប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុ ដើម្បីដឹកជញ្ជូនស្បៀងទៅឲ្យកងទ័ពកុម្មុយនិស្តយួននៅក្នុងស្រុកយួនខាងត្បូង រួចហើយពួកយួនខាងជើងនិងយៀកកុង ក៏បានទទួលនូវការអនុញ្ញាតឲ្យប្រើប្រាស់ខេត្តខ្មែរនៅទិសខាងកើត ធ្វើជាជំរកដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹង«ចក្រពត្តិអាមេរិកាំង»ផងដែរ ។ ស្តេចសីហនុបានបន្តកសាងចំណងមិត្តភាពរបស់ទ្រង់ជាមួយសាធារណរដ្ឋប្រជាមានិតចិន ហើយខាងចិនក៏បានទទួលស្គាល់លើកតម្លៃស្តេចសីហនុ ជាសម្ព័ន្ធមិត្តរបស់ខ្លួន ។ ក្នុងខែតុលា ឆ្នាំ១៩៦៥ ចិនបានអញ្ជើញស្តេចសីហនុទៅទីក្រុងប៉េកាំង ក្នុងឋានៈជាភ្ញៀវកិត្តិយសនៅក្នុងប្រារព្ធពិធីបុណ្យជាតិរបស់ខ្លួន ។

ពេញឆ្នាំ១៩៦៦និង១៩៦៧, ស្តេចសីហនុចេញផ្សាយសេចក្តីថ្លែងការណ៍ គាំទ្រជំហររបស់ក្រុងហាណូយ លើលក្ខខណ្ឌដំបូងដើម្បីធ្វើការចរចា និងទទួលស្គាល់នូវភាពស្របច្បាប់នៃ<រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង> ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ក្រុងហាណូយ ថាជាតំណាងត្រឹមត្រូវតែមួយគត់នៃប្រជាជនវៀតណាមខាងត្បូង ។ ជាឧទាហរណ៍, យោងតាមការផ្សាយនៃវិទ្យុហាណូយ, កាលពីខែមិនា១៩៦៧ ស្តេចសីហនុបានផ្ញើលិខិតមួយច្បាប់ ទៅជូនលេខាធិការនៃសន្និសិទត្រីទ្វីបនៅទីក្រុងហាវ៉ាណា «ផ្តន្ទាទោសសហរដ្ឋអាមេរិកយ៉ាងខ្លាំងក្លាចំពោះសង្គ្រាមឈ្លានពាននៅក្នុងស្រុកយួន ហើយនិងបញ្ចេញសម្លេងគាំទ្រយ៉ាងពេញទំហឹងរបស់ខ្មែរ ចំពោះការតស៊ូនៃប្រជាជនយួន ប្រឆាំងអំពើឈ្លានពានរបស់អាមេរិកាំង និងដើម្បីការស្រោចស្រង់ជាតិ» ។ នៅខែមេសាឆ្នាំ១៩៦៦, ស្តេចសីហនុបានលើកកម្រិតស្ថិតិបេសកកម្មពាណិជ្ជកម្មនៃសាធារណរដ្ឋសង្គមនិយមវៀតណាម (យួនខាងជើង), ដែលបានរៀបចំឡើងកាលពីខែកក្កដា១៩៦២ ឲ្យឡើងឋានៈទៅជាតំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ នៅថ្ងៃទី៨មិថុនា ១៩៦៧, សាធារណរដ្ឋសង្គមនិយមវៀតណាមបានចេញផ្សាយនូវសេចក្តីប្រកាសមួយ ៖ «ទទួលស្គាល់ និងសន្យាគោរពបូរណភាពទឹកដីកម្ពុជា នៅក្នុងរង្វង់ព្រំដែនបច្ចុប្បន្ន» ។ ក្រោយសេចក្តីថ្លែងការណ៍នេះបន្តិច ប្រហែលមួយអាទិត្យ បន្ទាប់ពីមានសេចក្តីថ្លែងការណ៍ស្រដៀងគ្នាធ្វើឡើងដោយ<គណៈកម្មាធិការមជ្ឈឹមនៃរណសិរ្សជាតិរំដោះវៀតណាម> (យៀកកុង), ស្តេចសីហនុបានផ្ញើលិខិតទៅ ង្វៀង-ហ៊ុយថូ, ប្រធានគណៈកម្មាធិការមជ្ឈឹមប្រេស៊ីឌីយ៉ូម និងផ្ញើទៅ ផាម-យ៉ាំងដុង, នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្នើដម្លើងទំនាក់ទំនងឲ្យទៅជាឋានៈទូត ជាមួយរាជាណាចក្រកម្ពុជា ។ រួចបន្ទាប់មក នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៦៧, មានសរាចរមួយចេញផ្សាយនៅក្រុងហាណូយប្រកាសឲ្យដឹង អំពីការរៀបចំទំនាក់ទំនងទូត រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយកម្ពុជា ។ ដូច្នេះ...នយោបាយការបរទេសរបស់ស្តេចសីហនុ ក៏ចាប់ផ្តើមទ្រេតយ៉ាងខ្លាំងទៅរកយួនខាងជើង » ។

ខាងក្រោមនេះជាឯកសារប្រវត្តិសាស្រ្ត បង្ហាញឲ្យឃើញអំពីទំនាក់ទំនងរវាងស្តេចសីហនុ ជាមួយយួនយៀកកុង-យៀកណាមខាងជើង ៖

## កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការបង់ប្រាក់រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋវៀតណាមខាងត្បូង

( បកប្រែក្រៅផ្លូវការ )

★ រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀងណាមខាងត្បូង មានការពេញចិត្តនិងបង្កទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ, ដោយបានសំរេចធ្វើនូវកិច្ចព្រមព្រៀងនេះ ។

★ ឧទ្ទេសនាមដើម្បីវត្ថុបំណងនេះ, តំណាងពេញអង្គខាងរាជរដ្ឋាភិបាលកម្ពុជា គឺឯកឧត្តមលោក ព្រំ-ថុស, រដ្ឋលេខាធិការក្រសួងពា-

ណិជ្ជកម្ម ។ តំណាងពេញអង្គខាងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង គឺឯកឧត្តមលោក ង្វៀង យ៉ាំងហ៊ីវ, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញអង្គនៃសាធារណរដ្ឋវៀតណាមខាងត្បូងប្រចាំប្រទេសកម្ពុជា ។

★ ហេតុដូច្នេះ, ប្រទេសទាំងពីរក្រោយអំពីបានទទួលស្គាល់តាមផ្លូវការត្រឹមត្រូវ នូវអំណាចពេញលេញរៀងខ្លួន បានព្រមព្រៀងតាមបទបញ្ញត្តិដូចតទៅ ៖

## មាត្រាទី១

រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង បានព្រមព្រៀងលើគោលការណ៍ជាមូលដ្ឋាន នៃការប្តូរស្មើភាពគ្នាទៅវិញទៅមក ដើម្បីជួយជំរុញនិងពង្រីករវាងប្រទេសទាំងពីរ នូវការនាំចូលនិងនាំចេញ ឥវ៉ាន់ដែលមានរាយនាមក្នុងបញ្ជីភ្ជាប់ <ក> និង <ខ> ភ្ជាប់មកជាមួយកិច្ចព្រមព្រៀងនេះ ហើយបញ្ជីនេះជាផ្នែកមួយនៅក្នុងកិច្ចព្រមព្រៀង ។

បញ្ជី <ក> រាយមុខឥវ៉ាន់ប្រុងប្រៀបទុកសំរាប់ដឹកនាំចេញពីព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅកាន់សាធារណរដ្ឋវៀតណាមខាងត្បូង ។

## មាត្រាទី២

ការប្តូរឥវ៉ាន់រវាងសាធារណរដ្ឋវៀតណាមខាងត្បូងនិងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើត្រឹមត្រូវតាមច្បាប់ និងបទបញ្ញត្តិនៅក្នុងក្របខ័ណ្ឌនៃរបៀបគ្រប់គ្រងទូទៅ ស្តីអំពីកានាំចូលនិងនាំចេញជាធរមាននៅក្នុងប្រទេសទាំងពីរ ។

រដ្ឋាភិបាលទាំងពីរបានព្រមព្រៀងនិងសម្រួលទៅវិញទៅមក ក្នុងករណីដែលអាចធ្វើទៅបាន និងក្នុងគោលការណ៍មិនប្រកាន់គ្នាទៅវិញទៅមក នូវការបំពេញទម្រង់បែបបទ ទាក់ទងនឹងលិខិតអនុញ្ញាត ព្រមទាំងទម្រង់បែបបទផ្នែកគយ ។

## មាត្រាទី៣

រដ្ឋាភិបាលទាំងពីរយល់ព្រមទៅវិញទៅមក ផ្តល់ឲ្យឥវ៉ាន់ដែលត្រូវប្តូរគ្នានេះ នូវការបន្ធូរបន្ថយយ៉ាងច្រើនដែលអាចធ្វើទៅបាន ។ របស់របរទាំងនេះ មានការបង់ពន្ធគយតាមក៏រិតទាប ។

## មាត្រាទី៤

ការបង់ប្រាក់ទាក់ទងនឹងសកម្មភាពពាណិជ្ជកម្មក្រោមកិច្ចព្រមព្រៀងនេះ និងការបង់ប្រាក់ដទៃទៀត រវាងប្រទេសទាំងពីរ ត្រូវធ្វើជា លីវស្ទឺលីង (ប្រាក់អង់គ្លេស) ឬជារូបិយប័ណ្ណដទៃទៀត ដែលអាចប្តូរដោយសេរី តាមច្បាប់បញ្ញត្តិជាធរមានក្នុងប្រទេសទាំងពីរផ្នែកការប្តូរប្រាក់ ។

ដូច្នេះហើយ រដ្ឋាភិបាកបដិវត្តន៍បណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង ចាត់តាំងធនាគារជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ជអ្នកកាន់គណនី ។

## មាត្រាទី៥

កិច្ចសន្យានិងវិក័យប័ត្រទាក់ទងនឹងការប្តូរឥវ៉ាន់ពាណិជ្ជកម្ម រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋវៀតណាមខាងត្បូង ព្រមទាំងឯកសារនិងបញ្ជាបង់ប្រាក់ រវាងប្រទេសទាំងពីរ ត្រូវសរសេរចេញជាលីវស្ទឺលីង ឬជារូបិយប័ណ្ណណាមួយដែលអាចប្តូរបាន យោងតាមប្រភពមាត្រាខាងលើនេះ ។

## មាត្រាទី៦

ប្រទេសណាមួយដែលបានព្រមព្រៀងតាមកិច្ចសន្យានេះ មិនអាចនាំចេញទៅប្រទេសទីបី នូវរបស់របរដែលបាននាំចូលពីប្រទេសណាមួយ ដោយឥតមានការយល់ព្រមពីប្រទេសនេះទេ ។

## មាត្រាទី៧

ដើម្បីធានាឲ្យកិច្ចព្រមព្រៀងនេះមានដំណើរល្អ គូភាគីទាំងសង្ខាងនឹងបង្កើតគណៈកម្មាធិការចំរុះ ដែលត្រូវប្រជុំតាមកាលកំណត់ តាមសំណើរបស់គូភាគីណាមួយ តាមគោលការណ៍ត្រូវធ្វើឆ្លាស់គ្នា ម្តងនៅកម្ពុជា ម្តងនៅប្រទេសវៀតណាមខាងត្បូង ។

គណៈកម្មាធិការនេះអាចសំរេចតម្លើងចំនួននៃការប្តូរទំនិញពាណិជ្ជកម្ម រវាងប្រទេសទាំងពីរនិងការកែប្រែ បើជាការចាំបាច់នៃបញ្ជីទំនិញទាំងពីរ ដែលមានភ្ជាប់ជាមួយកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី៨

កិច្ចព្រមព្រៀងនេះចូលជាធរមាន១៥ថ្ងៃ ក្រោយពេលដែលភាគីទាំងសង្ខាងបានយល់ព្រមទទួលស្គាល់ តាមរបៀបរដ្ឋធម្មនុញ្ញរៀងៗខ្លួន ។ កិច្ចព្រមព្រៀងនេះប្រើការបានក្នុងរយៈពេល១ឆ្នាំ ហើយត្រូវចាត់ទុកបន្តជាស្វ័យប្រវត្តិ ក្នុងរយៈពេល១ឆ្នាំជាបន្តបន្ទាប់ទៅទៀត លើកលែងតែគូភាគីណាមួយផ្តល់ដំណឹងតាមលិខិតទៅគូភាគីម្ខាក់ទៀត អំពីបំណងលប់កិច្ចព្រមព្រៀង ក្នុងរយៈពេល៣ខែមុនថ្ងៃដែលកិច្ចព្រមព្រៀងនេះត្រូវចប់ ។ កិច្ចព្រមព្រៀងនេះ អាចត្រូវតែផ្លាស់ប្តូរតាមការពិភាក្សា និងការប្តូរលិខិតជាផ្លូវការ រវាងគូភាគីទាំងសង្ខាង ។

ដោយគោរពតាមកិច្ចព្រមព្រៀងនេះ អ្នកតំណាងរដ្ឋពេញសមត្ថភាពទាំងសង្ខាងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ហើយបានប្រថាប់ត្រារៀងខ្លួន ។

ធ្វើនៅទីក្រុងភ្នំពេញ, ថ្ងៃទី២៥ កញ្ញា ១៩៦៩

ជាពីរច្បាប់ ជាភាសាវៀតណាម ខ្មែរ និងបារាំង, អត្ថបទទាំង៣នេះអាចប្រើបានទាំងអស់ ។ ក្នុងករណីវិវាទ អត្ថបទជាភាសាបារាំងត្រូវប្រើជាឯកសារសំរាប់ការបកស្រាយ ។

| | |
|---|---|
| សំរាប់ខាងរាជរដ្ឋាភិបាល<br>កម្ពុជា<br>ហត្ថលេខា ៖ ព្រុំ ថុស | សំរាប់ខាងរដ្ឋាភិបាល<br>រណសិរ្សបណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង<br>ហត្ថលេខា ៖ ង្វៀង យ៉ាំងហ៊ីវ |

សំរាប់លិខិតដើមជាផ្លូវការ
អគ្គនាយក
ហត្ថលេខា ៖ ឡុង-ជួន

## បញ្ជី "ក"

### ផលិតផលវៀតណាមអនុញ្ញាតនាំចេញទៅកម្ពុជា

★ ក- ផលិតផលកសិកម្ម

★ ខ- ផលិតផលឧស្សាហកម្ម

ចំនួនពិតប្រាកដនៃផលិតផលទាំងអស់នេះ នឹងធ្វើឡើងមួយករណីម្តងៗទៅតាមការដឹកជញ្ជូនចេញពិតប្រាកដ ដែលយោងតាមក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

\-------------

## បញ្ជី "ខ"

### ផលិតផលកម្ពុជាអនុញ្ញាតនាំចេញទៅវៀតណាមខាងត្បូង

★ អង្ករ

★ អំបិល

★ សាំង និងប្រេងខ្លាញ់គោ
★ ថ្នាំពេទ្យ

<u>ផលិតផលបន្ទាប់បន្សំជាម្ហូបអាហារ</u>

๑ សណ្តែកបាយ
★ សណ្តែកសៀង
★ ដើមល្ង
★ ល្ង
★ ត្រីឆ្អើរ, ត្រីប្រៃ និងត្រីងៀត
★ ម្ហូបម្សៅត្រី (ផលិតផលថ្មីរបស់ក្រុម SONACOP ។ ប្រហែលគេដាក់ថ្នាំទុកបានយូរនៅក្នុងនោះ ដូចជាត្រីផ្លាធូប្រៃនិងស្ងួតពីកោះកុង) ។
★ ម្សៅទឹកត្រី (ទឹកត្រីស្ងួត)
★ កាពិក
★ សាច់ប្រៃ
★ ខ្លាញ់ជ្រូក
★ ប្រេងល្ង
★ ស្ករស
★ ទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះគោ

<u>ផលិតផលឧស្សាហកម្មនៅក្នុងស្រុក</u>

★ កង់ និងគ្រឿងបន្លាស់កង់
★ គ្រឿងបន្លាស់រថយន្ត
★ ស្បែកជើងកៅស៊ូ
★ គ្រឿងប្រដាប់ប្រដារសំរាប់ប្រើប្រាស់
★ ប្រដាប់ប្រដារតូចតាច និងគ្រឿងបន្ទាប់បន្សំ
★ ស្រោមដៃស្រោមជើង – សំលៀកបំពាក់ផ្សេងៗ
★ ផ្ទាំងកៅស៊ូប្លាស្ទីក
★ មុង
★ ភួយ
★ ក្រណាត់កីមិនទាន់កាត់ ពណ៌ស–ខ្មៅ
★ ដែកសន្លឹក

តម្លៃសរុប ៖ **L 1.000.000**